ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៣៧៤......សហវ.....

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដោះស្រាយទំនាស់ពាក់ព័ន្ធការកាន់កាប់ដីរដ្ឋ ដែលស្ថិតក្រោមការប្រើប្រាស់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ដោយមន្ត្រី ០២ រូប នៃរតនាគារខេត្តកោះកុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៥៨ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារដោះស្រាយវិវាទពាក់ព័ន្ធការកាន់កាប់ដីរដ្ឋ ដែលស្ថិតក្រោមការប្រើប្រាស់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ដោយមន្ត្រី ០២ រូប នៃរតនាគារខេត្តកោះកុង ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈន សុគាត** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន | អនុប្រធាន |
| ៣. ឯកឧត្តម **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៤. ឯកឧត្តម **ម៉ិញ ចានសុវណ្ណអាទិច្ចសីលា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៥. លោកស្រី **លឹម ឈុនលី** | ប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៦. លោក **នេព ទិស្ថុល** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង | សមាជិក |
| ៧. លោកស្រី **សូច សុរិយា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោក **យិន ពិនាយ** | ប្រធានរតនាគារខេត្តកោះកុង | សមាជិក |
| ៩. លោក **លី សុខគីម** | ប្រធានការិយាល័យសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១០.លោក **ហ៊ុន ពិសិដ្ឋ** | អនុប្រធានការិយាល័យសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក ។ |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ជួបប្រជុំ និងដឹកនាំសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយវិវាទដែលកើតមានឡើង
- សិក្សាមូលដ្ឋានផ្លូវច្បាប់ និងលើកយោបល់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចាត់វិធានការរដ្ឋបាល និងវិធានការចាំបាច់ដទៃផ្សេងទៀត។
- សិក្សាវាយតម្លៃ និងចរចាជាមួយភាគីពាក់ព័ន្ធ លើប្រាក់ឧបត្ថម្ភគោលនយោបាយ ដែលនឹងត្រូវផ្តល់ជូន
- រៀបចំនិងស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួង លើគម្រោងថវិកាចំណាយលើប្រាក់ឧបត្ថម្ភគោលនយោបាយ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តការប្រគល់ទទួលទីតាំង និងការគ្រប់គ្រងទីតាំងដែលបានដោះស្រាយរួចទៅអាជ្ញាធរកាន់កាប់ដីរដ្ឋវិញ ក្រោយពេលបញ្ចប់ការងារសម្របសម្រួល និងដោះស្រាយវិវាទ
- រាយការណ៍អំពីលទ្ធផលការងារជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

សមាសភាព នៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំរបស់ក្រុមការងារនេះ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើ-ពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

[illegible]ភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ